# ពិធីសំណេះសំណាល និងណែនាំដល់និស្សិតទៅចូលរួមក្នុងកម្មវិធី

JENESYS 0.2 SCIENCE & TECHNOLOGY 25TH

(ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥នៅនាយកដ្ឋានបច្ចេកទេស វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា)

កាលពីព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ នាយកដ្ឋានបច្ចេកទេសវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា បានរៀបចំពិធីសំណេះសំណាល និងណែនាំដល់និស្សិតចំនួន ១០រូប ដែលនឹងត្រូវចូលរួមក្នុងកម្មវិធីឈ្មោះ បណ្តាញភ្ជាប់ទំនាក់ទំនងរវាងអាស៊ីបូពាហ៌ និងជប៉ុន ស្តីពី ការផ្លាស់ប្តូរបទពិសោធន៍ ចំណេះដឹង វប្បធម៌ និងទំនៀមទំលាប់ក្នុងចំណោមសិស្ស និងនិស្សិតវ័យក្មេងជំនាន់ក្រោយ (JAPAN-EAST ASIA NETWORK OF EXCHANGE FOR STUDENTS AND YOUTHS) ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ទឹង ស៊ីនី អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានគណៈកម្មាធិការជាតិ សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា** (NCOST) ។

កម្មវិធី (JAPAN-EAST ASIA NETWORK OF EXCHANGE FOR STUDENTS AND YOUTHS) នឹងចាប់ផ្តើមចាប់ពីថ្ងៃទី៣០ ខែមីនា ដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥ ខាងមុខ នេះនៅប្រទេសជប៉ុន

គោលបំណងនៃការរៀបចំកម្មវិធីនេះគឺដើម្បីណែនាំឲ្យនិស្សិតៈ

- ស្វែងយល់ឲ្យបានច្បាស់ពីកម្មវិធី (JAPAN-EAST ASIA NETWORK OF EXCHANGE FOR STUDENTS AND YOUTHS) វគ្គទី២៥
- ជ្រើសរើសប្រធាន និងអនុប្រធានក្រុមនិស្សិតកម្ពុជា
- រៀបចំសម្លៀកបំពាក់ និងសម្ភារៈចាំបាច់មួយចំនួន
- គោរពវិន័យ មានសីលធម៌ និងឥរិយាបថល្អ និងត្រូវសាមគ្គីគ្នាក្នុងពេលចូលរួមកម្មវិធី
- ចូលរួមយ៉ាងសកម្មក្នុងបណ្តាញទំនាក់ទំនងដើម្បីចែករំលែក ផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង និងបទពិសោធន៍ផ្នែកវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា ជាមួយនិស្សិតទាំងអស់មកពីបណ្តាប្រទេសនានាក្នុងតំបន់អាស៊ាន។

និស្សិតចំនួន ១០រូបខាងលើមកពីវិទ្យាស្ថាន និងសកលវិទ្យាល័យ នៃព្រះរាជាណាចក្រកម្ពុជារួមមាន ៖

- ROYAL UNIVERSITY OF FINE ART
- WESTERN UNIVERSITY
- NATIONAL UNIVERSITY OF MANAGEMENT
- BUILD BRIGHT UNIVERSITY
- NORTON UNIVERSITY
- INSTITUE OF TECHNOLOGY OF CAMBODIA
- NATIONAL INSTITUE OF BUSINESS

រូបភាព ស្តីពីកិច្ចសំណេះសំណាលរវាងនិស្សិត និង**ឯកឧត្តមបណ្ឌិត ទឹង ស៊ីនី អនុរដ្ឋលេខាធិការ**


ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
គណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន
ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (NCOST)
កិច្ចប្រជុំ
ជាមួយនិស្សិតទៅចូលរួមក្នុងកម្មវិធី
JENESYS 2.0 Science & Technology 25th Bath
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥



